N° 3 R. 11-6-52 2(80
" Kampuchéah soriya "
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

Mars

…ាំទី ២៤ ខែមីនា លេខ ៣

…ស. ២៤៩៤ — គ.ស. ១៩៥២

ក 80 ₂

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពន្លឺអាស៊ីទ្វីប (តមក) ............ | លោកភ័យ – ប៊ុក .......... | ១៦៣ |
| លោកិយលោកុត្តរបញ្ញាកថា ......... | ព្រះអាចារ្យ ទូច - ឃុង ..... | ១៧០ |
| អត្តានុទិដ្ឋិ ................... | នាកញ្ញា សំ – ស៊ុន ........ | ១៧៦ |
| កម្មវិភាគ ................... | ព្រះមហា ឧម - ត៉ាគ្រី ...... | ១៨២ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| ល្បើកក្រើនជាតិ ................ | លោក ប៊ូ - ប៊ូ .......... | ១៨៦ |
| ការបណ្ដុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង – ប៉ម ... | ១៨៩ |
| រឿងសាមកុក (តមក)........... | នាកញ្ញា នូ – កន .......... | ១៩៦ |
| រឿងអារក្សថ្លែងរឿងម្ភៃប្រាំ (តមក).... | លោក សាង – សាវ៉ាត ...... | ២០៤ |
| រឿងស្នេហាជាតិ (តមក)........... | លោក គង់ – លឹម.......... | ២១០ |
| រឿងប៉ូលនឹងវីរ៉ស៊ីនី ............... | សាស្ត្រាចារ្យ ផេង – ជ្រីវ ..... | ២២០ |
| សំលៀកបំពាក់ខ្មែរ ............... | ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ..... | ២២៤ |
| **កំណត់និងប្រវត្តិការណ៍** | | |
| ពិធីបុណ្យកឋិន នៅវិទ្យាល័យស៊ីសុវត្ថិភ្នំពេញ | ក្រុមសាស្ត្រាចារ្យនឹងក្រុមសិស្ស.. | ២៣១ |

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៨៣រ.០០

## លោកិយលោកុត្តរបញ្ញាកថា

### ព្រះអាចារ្យ ទូប-ទៀង វត្តកែវព្រះភ្លើង ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ រោចខែពិសាខ

ឆ្នាំជូតសំរិទ្ធិស័ក ព. ស. ២៤៩១ (៦-៣-៤៨)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ខ្ញុំព្រះករុណា សូមនមស្ការ ចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្ដីគោរព ។

**នត្ថិ បញ្ញាសមា អាភា**

ពន្លឺស្មើដោយបញ្ញា មិនមាន ។

បណ្ដាពន្លឺទាំងឡាយក្នុងលោក មានពន្លឺព្រះអាទិត្យ ព្រះចន្ទជាដើមនេះ គ្រាន់តែសម្រាប់បំភ្លឺភ្នែកមហាជនទាំងពួង ឲ្យឃើញបាន តែត្រឹមរូបផ្សេងៗប៉ុណ្ណោះ មិនអាចនឹងយល់នូវហេតុនិងផលនៃសេចក្ដីសុខ-ទុក្ខ ទាំងពួងក្នុងលោកនេះ និងលោកខាងមុខពុំបាន ។ ដូចឃើញថា ការប្រព្រឹត្តិសុចរិត ជាហេតុនៃសេចក្ដីសុខ, ការប្រព្រឹត្តិទុច្ចរិត ជាហេតុនៃសេចក្ដីទុក្ខដូច្នេះជាដើម នេះក៏អាស្រ័យដោយពន្លឺពោលគឺបញ្ញានេះឯង ទើបពិចារណាឃើញបាន ។

## ប្រភេទនៃបញ្ញាមាន ២ យ៉ាង គឺ:

១.— **លោកិយបញ្ញា** បញ្ញាសម្រាប់ប្រើការក្នុងលោកនេះ នៃជនជាបុថុជ្ជន ។

២ — **លោកុត្តរបញ្ញា** បញ្ញាសម្រាប់ពិចារណា នូវមគ្គនិងផល ដើម្បីចូលទៅកាន់ព្រះនិព្វាន នៃព្រះអរិយបុគ្គលជាម្ចាស់ ។

បញ្ញាឈ្មោះថាពន្លឺភ្លឺស្វាងរុងរឿង ជាងពន្លឺដែលមាននៅក្នុងលោកនេះទាំងមូល ។ ឯក្នុងលោកនេះទាំងមូល ហេតុជារបស់សំខាន់បំផុត បើបុគ្គលអ្នកស្គាល់នូវ "ហេតុ" បាន គេទុកជាមនុស្សសំខាន់បំផុត ។ ដូចស្គាល់ច្បាស់ថា: ការនាំឲ្យកើតភពជាតិកំណើតរបស់ខ្លួន មកពីលង់ទៅជាហេតុ, ការលង់ទៅមកពីគ្មានជម្រះវិជ្ជាសម្រាប់ដូរលោក-ដូរធម៌ជាហេតុ, ការគ្មានជម្រះវិជ្ជាមកពីការខ្ជិលជាហេតុ ។

ការខ្ជិលច្រអូស ជាមេជាដើមបណ្ដុះបណ្ដាលខាងបាប, សេចក្ដីព្យាយាម ជាមេបណ្ដុះបណ្ដាលខាងបុណ្យ ឲ្យចំរើនសព្វប្រការ ។

ឯជម្រះវិជ្ជានិងភោគសម្ប័ទ ជាហេតុបណ្ដុះបណ្ដាលឲ្យសម្រេចប្រយោជន៍បានច្រើនប្រការណាស់ ដូចក្នុងប្រទេសជាតិនិមួយ ៗ ដែលមានសេចក្ដីចំរើនសុខដុំធំទូលាយ ឡើងទៅកាន់ថ្នាក់ជាន់លើខ្ពស់ត្រដែតត្រប់ដំហានទៅបាននោះ ព្រោះមានជម្រះវិជ្ជាជាហេតុផង មានភោគ-សម្ប័ទជាហេតុផង ។

កុសលធម៌ ឃើញដូចព្រះបរមគ្រូរបស់យើង ដែលព្រះអង្គទ្រង់បំពេញព្រះបារមីមក ក៏អាស្រ័យគោតសម្ប័ទជាហេតុ ដូចកាលទ្រង់បំពេញ ទាន, សីល, នេក្ខម, បញ្ញា, វិរិយ, ខន្តិ, សច្ច, អធិដ្ឋាន, មេត្តា, ឧបេក្ខា; នេះអាស្រ័យគោតសម្ប័ទ ជាកំលាំង ជាគ្រឿងទំនុកបម្រុង ដល់បារមីធម៌ទាំង ១០ ប្រការ ឲ្យបានត្រាស់ដឹងជាព្រះពុទ្ធនេះឯង ។

ចំណែកសាវក - សាវិកាទាំងឡាយរបស់ព្រះអង្គ ក៏អាស្រ័យកំឡាំងគោតសម្ប័ទ ជាហេតុដូចគ្នា គួរយ៉ាងដូចអគ្គសាវកទាំងគូរបស់ព្រះអង្គ គឺព្រះមហាសារីបុត្តត្ថេរ កាលកើតជាសរទតាបសក្តី ព្រះមហាមោគ្គល្លានត្ថេរ កាលកើតជាសិរិវឌ្ឍកុដុម្ពិកៈក្តី លោកទាំងពីរនេះសុទ្ធតែមានគោតសម្ប័ទ មានខ្ទឹមច្រើនកប់មិនអស់ បានចំណាយឲ្យទានកសាងបុណ្យ កសាងកុសលច្រើនប្រការណាស់ បានតាំងប្រាថ្នាជាអគ្គសាវករបស់ព្រះអង្គ មកបានសម្រេចដូចសេចក្តីប្រាថ្នា ក៏ឃើញថាអាស្រ័យគោតសម្ប័ទជាហេតុ ឲ្យបំពេញសាវកបារមីញាណដែរ ។

ព្រះអរិយសាវករបស់ព្រះអង្គឈ្មោះអនាថបិណ្ឌិកក្តី ព្រះអរិយសាវិកាឈ្មោះវិសាខាមហាឧបាសិកាក្តី លោកទាំងនេះសុទ្ធតែមានគោតសម្ប័ទស្តុកស្តម្ភម៉ាំមួនណាស់ ទាល់តែល្បីពេញក្នុងលោក ក៏អាស្រ័យគោតសម្ប័ទជាហេតុ ឲ្យមានឧបនិស្ស័យនៃសោតាបត្តិមគ្គ ឲ្យថ្លៃថ្លាខ្ពង់ខ្ពស់កល់ជាតិដកបដល់ទីបំផុត នៃលោកុត្តរសម្បត្តិយ៉ាងនេះ ក៏អាស្រ័យកំលាំងគោតសម្ប័ទជាហេតុដូចគ្នា ។

មនុស្សជាតិម្នាក់ៗ ដែលបានកើតមកជាមនុស្សហើយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ត្រូវផ្តល់ខ្លួនតាមវ័យរបស់ខ្លួន ទើបចំរើនជាសុខបាន ។

បុគ្គលឯណាផ្តល់ខ្លួនឯងមិនត្រូវតាមវ័យរបស់ខ្លួន បុគ្គលនោះមុខជាបានទុក្ខយ៉ាងធ្ងន់ ។ ឯវ័យនោះមាន ៣ បើតាមគម្ពីរវិសុទ្ធិមគ្គត្រង់បញ្ញានិទ្ទេសព្រះពុទ្ធឃោសាចារ្យ លោកកំណត់យកតាមអាយុរបស់មនុស្សចំនួន ១០០ ឆ្នាំ មកចែងជា ៣ ជាន់ គឺជំនាន់ដំបូងកំណត់តាំងពីឆ្នាំដែលកើតរៀងទៅដល់អាយុ ៣៣ ឆ្នាំ ហៅថា "បឋមវ័យ" វ័យជាដំបូងនេះ ត្រូវស្វះស្វែងរករៀនជម្រះវិជ្ជាឲ្យចេះដឹងអក្សរសាស្ត្រសម្រាប់កត់ត្រាផ្សេងៗ ឲ្យចេះភាសាសាសន៍ សម្រាប់និយាយដោះស្រាយការផ្សេងៗ ឆ្លើយឆ្លងទាក់ទងទៅវិញទៅមករកគ្នានៃមនុស្សជាតិផ្សេងៗ ឲ្យចេះលេខ-ក្បាច់នព្វន្ត សម្រាប់គិតគូររកក់ព្រៀការងារទាំងពួង, ឲ្យចេះជញ្ជីងនាឡិ-ហាប រង្វាស់រង្វាល់ជាដើម សម្រាប់លក់ដូរជួញប្រែកែខ ចំណូលចំណាយឲ្យចេះស្ទាត់ជំនាញក្នុងបឋមវ័យនេះ ។

ជំនាន់ទីពីរតាំងពីអាយុ ៣៤ ឆ្នាំ រៀងទៅដល់អាយុ ៦៧ ឆ្នាំ ហៅថា "មជ្ឈិមវ័យ" គឺវ័យតាំងនៅជាកណ្ដាលនេះ ជាវ័យត្រូវយកជម្រះវិជ្ជារបស់ខ្លួននោះ មកតាំងព្យាយាមខំប្រឹងខ្នះខ្នែងស្វែងរកភោគសម្បូរ ដោយជំនួញជួញប្រែ តាមផ្លូវទឹក-ផ្លូវគោក សន្សំទុកដាក់ទ្រព្យសម្បូរ

មាននៅកុះករឡើង ឬ នឹងពង្រីកទ្រព្យសម្បត្តិដែលរកបាននោះ ឲ្យមានប្រយោជន៍ធំទូលាយតទៅ ។

ជំនាន់ទី ៣ គឺកំណត់តាំងពីអាយុ ៦៨ ឡើងទៅដល់អាយុ ១០០ ឆ្នាំ ហៅថាបច្ឆិមវ័យ" គឺវ័យតាំងនៅទីបំផុត វ័យនេះមិនមែនជាវ័យត្រូវរកត្រូវរៀនទេ ប្រាកដជាវ័យត្រូវទទួលផលជាសុខគ្រប់ប្រការ អំពីគុណជម្រេះវិជ្ជានិងផលនៃភោគសម្បទ ។

កាលបើបុគ្គលដំកល់ខ្លួនមិនត្រូវតាមវ័យ បឋមវ័យជាវ័យត្រូវរៀនសូត្រជម្រេះវិជ្ជា ត្រឡប់ទៅជាតាំងខ្លួនស៊ីផឹក ដើរលេងល្បែងផ្តេសផ្តាស ទាល់តែខ្លួនកន្លងផុតបឋមវ័យនេះទៅ ខ្លួនក៏ធ្លាក់ចុះទៅក្នុងកណ្តាប់ដៃល្ងង់ខ្លៅ ។

កាលតាំងនៅក្នុងមជ្ឈិមវ័យ គឺជាវ័យត្រូវរកភោគសម្បទ ត្រឡប់ជាស្វះស្វែងរករៀនជម្រេះវិជ្ជាវិញ ធ្វើម្តេចនឹងបានទាន់ពេលសម័យយកវិជ្ជាការនោះ មកប្រើការបានដូចបំណង ឬ ជារវល់ប្រព្រឹត្តលេងអបាយមុខដែលជាគ្រឿងនាំមកនូវសេចក្តីវិនាស, គឺជាអ្នករវល់នឹងលេងស្រី ជាអ្នករវល់លេងស៊ីផឹកៗស្រា ជក់អាភៀន គ្រឿងញៀន - គ្រឿងស្រវឹង, ជាអ្នករវល់លេងល្បែងស៊ី - សង ។ ជាអ្នករវល់ដើរលេងជាមួយនឹងមនុស្សពាល - អាក្រក់ យកមកជាមិត្តរបស់ខ្លួន ។ គ្មានបានឱកាសរកទ្រព្យសម្បត្តិអ្វីសោះ ទាល់តែខ្លួនកន្លងផុតមជ្ឈិមវ័យនេះទៅ ក៏ធ្លាក់ចុះទៅកណ្តាប់ដៃនៃសេចក្តីក្រហេមរហាមកើតទុក្ខវេទនាជាទីបំផុត ។

កាលតាំងនៅក្នុងបច្ឆិមវ័យ ជាវ័យត្រូវបុគ្គលទទួលផល គឺសេចក្តីសុខគ្រប់យ៉ាង ៗ ឯបុគ្គលខ្ជិលបានសេចក្តីសុខអំពីណា ព្រោះរវល់តែដេកថ្ងូរអំពីល្ងង់ នឹងសេចក្តីទ័ទ័លក្រផកបផល់ស្លាប់ប៉ុណ្ណោះ ៗ

បុគ្គលសេពគប់ជនពាល រមែងលិចចុះក្នុងសេចក្តីវិនាសក្នុងលោកនេះនឹងលោកខាងមុខ ៗ បុគ្គលសេពគប់ជនជាបណ្ឌិត រមែងដល់នូវសេចក្តីចំរើនក្នុងលោកនេះ នឹងលោកខាងមុខជាប្រាកដ ៗ ដូចបានសំដែងមកហើយពីខាងលើនេះ សូមឲ្យពុទ្ធបរិស័ទនឹងយុវជន-យុវនារីរួមជាតិទាំងឡាយ ស្ទុះក្រោកឡើងចាកសេចក្តីខ្ជិល បូវចំតាំងខ្លួនរៀបខ្លួនប្រកបកិច្ច ឲ្យត្រូវតាមលំដាប់វ័យ ដែលបានសំដែងមកនេះចុះទើបអ្នកនឹងបានចំរើនក្នុងលោកនេះ នឹងលោកខាងមុខជាប្រាកដមិនខាន ៗ

ធម៌ទេសនាចប់ប៉ុណ្ណោះ

## សប្បុរិសានំ សុភំ ហោតុ វឌ្ឍន្តុ សព្វេបិ ពុទ្ធសាសនេ

សូមសេចក្តីល្អគ្រប់យ៉ាង ចូរមានដល់អស់លោក-អ្នកសប្បុរសទាំង-ឡាយគ្រប់ពេលវេលាកុំបីចន្លោះ សូមឲ្យពួកពុទ្ធបរិស័ទគ្រហស្ថ-បព្វជិតទាំងអស់ ចំរើនសុខសួស្តីជយមង្គលក្នុងព្រះពុទ្ធសាសនាទៅហោង ៗ

ចប់